Khmer | ភាសាខ្មែរ

# ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាសម្រាប់ឆ្នាំ 2025



ការចាប់ផ្តើមចូលរៀននៅសាលា គឺជាពេលវេលាដ៏រំភើបមួយសម្រាប់កូនៗ ឪពុកម្តាយ និងអ្នកថែទាំ។ យើងចង់ជួយឱ្យដំណើរការចុះឈ្មោះចូលរៀនមានភាពងាយស្រួល តាមដែលអាចធ្វើទៅបាន សម្រាប់អ្នក។

នៅក្នុងរដ្ឋវិចថូរៀ កូនរបស់អ្នកមានសិទ្ធិចូលរៀននៅសាលាជិតខាងដែលបានកំណត់របស់ពួកគេ ('សាលារៀនក្នុងតំបន់' របស់អ្នក) នៅក្រោម *ច្បាប់កំណែទម្រង់ការអប់រំ និងការបណ្តុះបណ្តាលឆ្នាំ 2006*។

អ្នកក៏អាចដាក់ពាក្យសុំចូលរៀននៅសាលារៀនដែលមិនមែនជាសាលាក្នុងតំបន់របស់អ្នកបានផងដែរ។ សាលារៀននឹងពិចារណាលើពាក្យសុំរបស់អ្នក ស្របតាមគោលការណ៍ផ្តល់ទីកន្លែងចូលរៀន។ សម្រាប់ព័ត៌មានបន្ថែមអំពីគោលការណ៍ផ្តល់ទីកន្លែងចូលរៀន សូមចូលមើលទំព័រ ការចុះឈ្មោះចូលរៀននៅសាលា។

## តារាងពេលវេលាថ្មីនៅទូទាំងរដ្ឋ សម្រាប់ថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម។)

ឆ្នាំដំបូងនៃសាលាបឋមសិក្សាត្រូវបានគេហៅថាថ្នាក់មូលដ្ឋាន ឬថ្នាក់ត្រៀម។ យើងបានចេញផ្សាយតារាងពេលវេលាចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋានសម្រាប់សាលាបឋមសិក្សារដ្ឋក្នុងរដ្ឋវិចថូរៀទាំងអស់ដើម្បីអនុវត្តតាម (សូមមើលទំព័រ 3)។ តារាងពេលវេលាមានគោលបំណងជួយអ្នកឱ្យយល់ដឹងអំពីពេលវេលា និងរបៀបចុះឈ្មោះកូនរបស់អ្នកចូលរៀនក្នុងថ្នាក់មូលដ្ឋាន សម្រាប់ឆ្នាំសិក្សា 2025។

## តើពេលណាខ្ញុំគួរចុះឈ្មោះកូនរបស់ខ្ញុំចូលរៀននៅសាលាបឋមសិក្សា?

កូនរបស់អ្នកត្រូវមានអាយុ 5 ឆ្នាំ ត្រឹមថ្ងៃទី 30 ខែមេសា ក្នុងឆ្នាំដែលពួកគេចាប់ផ្តើមចូលរៀន។

ការចូលរៀននៅសាលាគឺជាកាតព្វកិច្ចសម្រាប់កុមារដែលចូលអាយុ 6 ឆ្នាំ។

ដើម្បីចុះឈ្មោះកូនរបស់អ្នកនៅក្នុងសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋវិចថូរៀសម្រាប់ឆ្នាំសិក្សា 2025 សូមដាក់បញ្ជូនពាក្យសុំចុះឈ្មោះចូលរៀននៅសាលាត្រឹមថ្ងៃទី 26 ខែកក្កដា ឆ្នាំ 2024។

## តើខ្ញុំអាចចុះឈ្មោះកូនរបស់ខ្ញុំក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលាបឋមសិក្សាដោយរបៀបណា?

សូមអនុវត្តតាមជំហានទាំងនេះ ដើម្បីចុះឈ្មោះកូនរបស់អ្នកក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលាបឋមសិក្សា៖

1. ស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ Find my School (ស្វែងរកសាលារៀនរបស់ខ្ញុំ) (សូមមើលខាងក្រោម)។
2. ទាក់ទងសាលាបឋមសិក្សារដ្ឋ ដើម្បីណាត់សុំទស្សនកិច្ចសាលា ឬដើម្បីស្វែងយល់បន្ថែមអំពីសាលា និងដំណើរការចុះឈ្មោះចូលរៀន។
3. ទាញយកកញ្ចប់ព័ត៌មានការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) ពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។ កញ្ចប់នឹងមានផ្តល់ជូនចាប់ពីថ្ងៃចន្ទ ទី 15 ខែមេសា ឆ្នាំ 2024 ហើយនឹងរួមបញ្ចូលទម្រង់បែបបទដាក់ពាក្យសុំ។ សាលាក៏អាចផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងនៃទម្រង់បែបបទមួយដើម្បីបំពេញផងដែរ។
4. ដាក់បញ្ជូនពាក្យចុះឈ្មោះចូលរៀនសម្រាប់ថ្នាក់មូលដ្ឋាន **ត្រឹមថ្ងៃសុក្រ ទី 26 ខែ កក្កដា ឆ្នាំ 2024**។
5. អ្នកនឹងត្រូវបានគេជូនដំណឹងអំពីលទ្ធផលនៃការដាក់ពាក្យសុំរបស់អ្នក **នៅរវាងថ្ងៃចន្ទ ទី 29 ខែកក្កដា និងថ្ងៃសុក្រ ទី 9 ខែសីហា ឆ្នាំ 2024**។ ប្រសិនបើអ្នកទទួលបានការផ្តល់ជូន អ្នកគួរតែទទួលយកការផ្តល់ជូននេះ **ត្រឹមថ្ងៃសុក្រ ទី 23 ខែសីហា ឆ្នាំ 2024**។
6. ចូលរួមនៅក្នុងវគ្គផ្តល់ព័ត៌មានចុះឈ្មោះ និងការធ្វើអន្តរកាល **ក្នុងអំឡុងត្រីមាសទី 4 ឆ្នាំ 2024**។
7. កូនរបស់អ្នកនឹងចាប់ផ្តើមថ្នាក់មូលដ្ឋាន **ពីថ្ងៃពុធទី 29 ខែមករា ឆ្នាំ 2025**។

## តើខ្ញុំស្វែងរកសាលារៀនក្នុងតំបន់របស់ខ្ញុំដោយរបៀបណា?

អ្នកអាចស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ Find My School (ស្វែងរកសាលារៀនរបស់ខ្ញុំ) ដោយធ្វើតាមជំហានខាងក្រោម៖

1. វាយបញ្ចូល findmyschool.vic.gov.au ទៅក្នុងកម្មវិធីរុករករបស់អ្នក។
2. វាយបញ្ចូលអាសយដ្ឋានរស់នៅអចិន្ត្រៃយ៍របស់អ្នកនៅក្រោមពាក្យ ‘Enter your address to get started (បញ្ចូលអាសយដ្ឋានរបស់អ្នកដើម្បីចាប់ផ្តើម)’។
3. ជ្រើសរើសឆ្នាំ 2025 នៅក្រោម ‘Enrolment year (ឆ្នាំចុះឈ្មោះចូលរៀន)’។ **ចំណាំ៖** តំបន់សាលារៀនឆ្នាំ 2025 នឹងមានផ្តល់ជូននៅចុងត្រីមាសទី 1 ឆ្នាំ 2024។
4. ជ្រើសរើសបឋមសិក្សានៅក្រោមពាក្យ 'School type'។

បន្ទាប់មកផែនទីនឹងបង្ហាញអាសយដ្ឋានរបស់អ្នក សាលារៀនក្នុងតំបន់របស់អ្នក ហើយនៅផ្នែកខាងឆ្វេងនឹងបង្ហាញពីព័ត៌មានទំនាក់ទំនងលម្អិតរបស់សាលារៀន។ ប្រសិនបើអ្នករំកិលចុះក្រោម វាក៏នឹងបង្ហាញអ្នកនូវសាលារៀនចំនួនប្រាំដែលនៅក្បែរអាសយដ្ឋានរបស់អ្នកបំផុត។

អ្នកក៏អាចស្វែងរកតាមឈ្មោះសាលារៀនផងដែរនៅក្រោមពាក្យ 'Search for school (ស្វែងរកសាលារៀន)'។

## តើកូនរបស់ខ្ញុំអាចដាក់ពាក្យទៅសាលាបឋមសិក្សារដ្ឋដែល មិនមែន ជាសាលាក្នុងតំបន់របស់យើងបានទេ?

បាន អ្នកអាចដាក់ពាក្យសុំទៅសាលារៀន ក្រៅពីសាលារៀនក្នុងតំបន់របស់អ្នកបាន។
សាលារៀននឹងពិចារណាពាក្យសុំរបស់អ្នកស្របតាមគោលការណ៍ផ្តល់ទីកន្លែងចូលរៀន និងកន្លែងទំនេរ។
អ្នកអាចស្វែងរកព័ត៌មានស្តីពីរបៀបដែលពាក្យសុំត្រូវបានផ្តល់ជាអាទិភាពនៅលើទំព័រ ការចុះឈ្មោះចូលរៀននៅសាលា។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំទទួលបានសំបុត្រមួយ ដែលនិយាយថា ពាក្យសុំចុះឈ្មោះរបស់ខ្ញុំមិនបានជោគជ័យ?

អ្នកគួរតែដាក់ពាក្យសុំចុះឈ្មោះចូលរៀនរបស់កូនអ្នកនៅសាលាផ្សេងទៀត។ កូនរបស់អ្នកត្រូវបានធានាឱ្យចូលរៀន
នៅសាលារៀនក្នុងតំបន់ របស់ពួកគេ។
សាលារៀនក្នុងតំបន់របស់កូនអ្នកត្រូវបានកំណត់ដោយផ្អែកលើអាសយដ្ឋានរស់នៅអចិន្ត្រៃយ៍របស់ពួកគេ។ ចូលមើលមើល Find my School
ដើម្បីកំណត់ទីតាំងសាលាក្នុងតំបន់របស់កូនអ្នក។ ទំព័រ ចុះឈ្មោះចូលរៀននៅសាលា ក៏អាចជួយអ្នកក្នុងការបញ្ជាក់អាសយដ្ឋាន
របស់កូនអ្នកសម្រាប់ការចុះឈ្មោះចូលរៀនផងដែរ។

អ្នកក៏អាចធ្វើការតវ៉ាលើការសម្រេចចិត្តផងដែរ។ ទំព័រ ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)
មានព័ត៌មានអំពីដំណើរការប្តឹងជំទាស់លើលទ្ធផលនៃការដាក់ពាក្យសុំចុះឈ្មោះចូលរៀន។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំខកខានចំពោះពេលវេលាចុះឈ្មោះចូលរៀន?

អ្នកអាចដាក់ពាក្យសុំចុះឈ្មោះកូនរបស់អ្នកចូលរៀនថ្នាក់មូលដ្ឋានសម្រាប់ឆ្នាំសិក្សា 2025 នៅពេលណាក៏បានចាប់ពីត្រីមាសទី 2 ឆ្នាំ 2024។

ខណៈពេលដែលអ្នកត្រូវបានស្នើសុំឱ្យដាក់ពាក្យបញ្ជូនសុំចុះឈ្មោះចូលរៀនត្រឹមថ្ងៃសុក្រ ទី 26 ខែកក្កដា ឆ្នាំ 2024
ពាក្យសុំក្រោយកាលបរិច្ឆេទនេះនឹងនៅតែត្រូវបានទទួលយកពីគ្រួសារទាំងនោះដែលខកខានចំពោះពេលវេលាចុះឈ្មោះចូលរៀន
ដែលផ្លាស់ប្តូរទីលំនៅអចិន្ត្រៃយ៍ ឬទើបមកដល់រដ្ឋវិចថូរៀក្នុងពេលថ្មីៗ។

ពាក្យសុំចុះឈ្មោះចូលរៀនដែលបានដាក់បញ្ជូនក្រោយថ្ងៃទី 26 ខែកក្កដា ឆ្នាំ 2024 នឹងត្រូវដំណើរការដោយសាលារៀននៅពេលដែល
ពួកគេបានទទួល ដោយអនុលោមតាមគោលការណ៍ផ្តល់ទីកន្លែងចូលរៀនរបស់ក្រសួង។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សានៅឯណា?

អ្នកអាចសួរសាលាបឋមសិក្សាក្នុងតំបន់របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន។

នៅដើមត្រីមាសទី 2 ឆ្នាំ 2024 អ្នកក៏អាចស្វែងរកកញ្ចប់ព័ត៌មានអំពីដំណើរការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋានផងដែរនៅលើទំព័រ
ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែកញ្ចប់ព័ត៌មាន សូមនិយាយទៅកាន់សាលាបឋមសិក្សាក្នុងតំបន់របស់អ្នកដើម្បីសុំជំនួយ។

## តើខ្ញុំត្រូវទាក់ទងអ្នកណាដើម្បីសុំជំនួយ?

អ្នកសម្របសម្រួលការផ្ទេរអន្តរកាល មន្ត្រីចុះឈ្មោះ ឬនាយកសាលាបឋមសិក្សាដែលអ្នកចង់ដាក់ពាក្យសុំ
អាចជួយអ្នកដើម្បីឆ្លើយតបនឹងសំណួរណាមួយដែលអ្នកចង់សួរ អំពីដំណើរការចុះឈ្មោះ។

## តំណភ្ជាប់ដែលមានប្រយោជន៍

សូមស្វែងរកតំណភ្ជាប់ដែលមានប្រយោជន៍មួយចំនួនខាងក្រោម ដែលអាចមានប្រយោជន៍សម្រាប់អ្នក
នៅពេលដែលកូនរបស់អ្នកចាប់ផ្តើមចូលរៀននៅសាលាបឋមសិក្សានៅឆ្នាំ 2025៖

Find my School (ស្វែងរកសាលារៀនរបស់ខ្ញុំ) – findmyschool.vic.gov.au
ព័ត៌មានអំពីតំបន់សាលារៀន – vic.gov.au/school-zones
ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) – vic.gov.au/enrolling-foundation-prep
ការចុះឈ្មោះចូលរៀននៅសាលា – vic.gov.au/how-choose-school-and-enrol
ពិការភាព និងការអប់រំមានលក្ខណៈរួមបញ្ចូល – vic.gov.au/disability-and-inclusive-education
ទំនាក់ទំនងការិយាល័យប្រចាំតំបន់ – vic.gov.au/office-locations-department-education

# តារាងពេលវេលាសម្រាប់ឆ្នាំ 2024-25

| កាលបរិច្ឆេទ ឆ្នាំ 2024 | សកម្មភាព |
|---|---|
| **ត្រីមាសទី 2៖ ថ្ងៃចន្ទ ទី 15 ខែមេសា ឆ្នាំ 2024 ដល់ថ្ងៃសុក្រ ទី 28 ខែមិថុនា ឆ្នាំ 2024** | |
| **ត្រីមាសទី 1 និងទី 2 ឆ្នាំ 2024** | សាលាបឋមសិក្សារៀបចំដំណើរទស្សនកិច្ច វគ្គផ្តល់ព័ត៌មាន និងសកម្មភាពផ្សេងទៀតសម្រាប់ក្រុមគ្រួសារដែលស្វែងរក ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) សម្រាប់កូនរបស់ពួកគេក្នុងឆ្នាំ 2025។ |
| **ត្រឹមដើមត្រីមាសទី 2 ឆ្នាំ 2024** | តំបន់សាលារៀនសម្រាប់ឆ្នាំសិក្សា 2025 ចុះផ្សាយផ្ទាល់នៅលើគេហទំព័រ findmyschool.vic.gov.au<br>ឪពុកម្តាយ និងអ្នកថែទាំគួរតែចូលទៅកាន់គេហទំព័រ findmyschool.vic.gov.au ដើម្បីកំណត់ទីតាំងសាលារៀនដែលបានកំណត់របស់ពួកគេ (សាលារៀនក្នុងតំបន់) សម្រាប់ឆ្នាំ 2025។<br>កញ្ចប់ព័ត៌មានចុះឈ្មោះសម្រាប់ឪពុកម្តាយ និងអ្នកថែទាំគឺអាចទាញយកបានពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។ |
| **ចាប់ពីសប្តាហ៍ទី 1 ត្រីមាសទី 2 ឆ្នាំ 2024** | សាលាបឋមសិក្សាអាចចែកចាយកញ្ចប់ព័ត៌មានចុះឈ្មោះចូលរៀនដល់គ្រួសារអនាគត និងសហគមន៍ក្នុងតំបន់របស់ពួកគេ។ |
| **ចាប់ពីសប្តាហ៍ទី 1 ត្រីមាសទី 2 ឆ្នាំ 2024** | **បើកទទួលពាក្យសុំចុះឈ្មោះចូលរៀន** – ឪពុកម្តាយ និងអ្នកថែទាំដាក់បញ្ជូនពាក្យសុំចុះឈ្មោះចូលរៀនដែលបានបំពេញចប់សព្វគ្រប់របស់ពួកគេទៅសាលាបឋមសិក្សារដ្ឋចាប់ពីកាលបរិច្ឆេទនេះ។ |
| **ត្រីមាសទី 3៖ ថ្ងៃចន្ទ ទី 15 ខែកក្កដា ឆ្នាំ 2024 ដល់ថ្ងៃសុក្រ ទី 20 ខែកញ្ញា ឆ្នាំ 2024** | |
| **ត្រឹមថ្ងៃសុក្រ ទី 26 ខែកក្កដា ឆ្នាំ 2024** | **ពាក្យសុំចុះឈ្មោះចូលរៀនដល់កំណត់** - ឪពុកម្តាយ និងអ្នកថែទាំដាក់បញ្ជូនពាក្យសុំចុះឈ្មោះចូលរៀនដែលបានបំពេញចប់សព្វគ្រប់របស់ពួកគេទៅសាលាបឋមសិក្សារដ្ឋត្រឹមកាលបរិច្ឆេទនេះ។ |
| **រវាងថ្ងៃចន្ទ ទី 29 ខែកក្កដា ដល់ថ្ងៃសុក្រ ទី 9 ខែសីហា ឆ្នាំ 2024** | សាលាបឋមសិក្សាជូនដំណឹងដល់ឪពុកម្តាយ និងអ្នកថែទាំជាលាយលក្ខណ៍អក្សរអំពីលទ្ធផលចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) ស្របតាមគោលការណ៍ផ្តល់ទីកន្លែងចូលរៀនរបស់ក្រសួង។ នេះអាចរួមបញ្ចូលលិខិតផ្តល់ជូនកន្លែងរៀន លិខិតបញ្ជាក់ការចុះឈ្មោះចូលរៀន ឬលិខិតនៃការដាក់ពាក្យសុំមិនបានជោគជ័យ។<br>ឪពុកម្តាយ និងអ្នកថែទាំបានផ្ញើលិខិតដាក់បញ្ជូនពាក្យដែលមិនបានជោគជ័យអាចចាប់ផ្តើមដាក់បញ្ជូនបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅសាលាបឋមសិក្សា។ |
| **ត្រឹមថ្ងៃសុក្រ ទី 23 ខែសីហា ឆ្នាំ 2024** | ឪពុកម្តាយ និងអ្នកថែទាំបានផ្ញើលិខិតផ្តល់ជូនកន្លែងរៀន បង្ហាញពីការទទួលយកកន្លែងរៀនរបស់កូនពួកគេត្រឹម កាលបរិច្ឆេទនេះ។ |
| **ត្រឹមថ្ងៃសុក្រ ទី 23 ខែសីហា ឆ្នាំ 2024** | **កាលបរិច្ឆេទបិទ** សម្រាប់ឪពុកម្តាយ និងអ្នកថែទាំដើម្បីដាក់បញ្ជូនបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅកាន់សាលាបឋមសិក្សា។ |
| **ត្រឹមថ្ងៃសុក្រ ទី 6 ខែកញ្ញា ឆ្នាំ 2024** | សាលាបឋមសិក្សាជូនដំណឹងដល់ឪពុកម្តាយ និងអ្នកថែទាំទាំងអស់ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃបណ្តឹងជំទាស់ របស់ពួកគេត្រឹមកាលបរិច្ឆេទនេះ។ |
| **ត្រឹមថ្ងៃសុក្រ ទី 20 ខែកញ្ញា ឆ្នាំ 2024** | **កាលបរិច្ឆេទបិទ** សម្រាប់ឪពុកម្តាយ និងអ្នកថែទាំដើម្បីដាក់បណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរជាមួយនាយកតាមតំបន់ ដែលពាក់ព័ន្ធ ដែលពួកគេមិនបានទទួលជោគជ័យជាមួយនឹងបណ្តឹងជំទាស់របស់ពួកគេទៅកាន់សាលាបឋមសិក្សា។ |
| **ត្រីមាសទី 4៖ ថ្ងៃចន្ទ ទី 7 ខែតុលា ឆ្នាំ 2024 ដល់ថ្ងៃសុក្រ ទី 20 ខែធ្នូ ឆ្នាំ 2024** | |
| **ក្នុងអំឡុងត្រីមាសទី 4 ឆ្នាំ 2024** | សាលាបឋមសិក្សានឹងរៀបចំវគ្គអន្តរកាល។ |
| **ត្រឹមថ្ងៃសុក្រ ទី 1 ខែវិច្ឆិកា ឆ្នាំ 2024** | ការិយាល័យប្រចាំតំបន់ជូនដំណឹងដល់ឪពុកម្តាយ និងអ្នកថែទាំទាំងអស់ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃបណ្តឹងជំទាស់ របស់នាយកសាលតាមតំបន់ត្រឹមកាលបរិច្ឆេទនេះ។ ការនេះអនុវត្តចំពោះតែបណ្តឹងជំទាស់ដែលទទួលបានត្រឹម ថ្ងៃបិទនៅថ្ងៃសុក្រ ទី 20 ខែកញ្ញា ឆ្នាំ 2024 ប៉ុណ្ណោះ។ |